ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៣ ស.រ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍
ចូល លេខ 390 គ.ជ.ណា
ថ្ងៃទី 28 ខែ06 ឆ្នាំ1997
ម៉ោង 8:00 នាទី

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ១៩៩៧

## សារាចរ

ស្តីពីបែបបទ និងនីតិវិធីនៃការស្នើសុំរួចពន្ធឧបករណ៍សំភារៈនាំចូល
ក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និង ជំនួយមនុស្សធម៌

* * * * *

កន្លងមក រាជរដ្ឋាភិបាលបានពិនិត្យឃើញ មានការយឺតយ៉ាវខ្លះក្នុងការស្នើសុំ និងដោះស្រាយអោយរួចពន្ធនូវការនាំចូលឧបករណ៍ សំភារៈក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និងជំនួយមនុស្សធម៌ ដែលជាមូលហេតុមួយធ្វើអោយការអនុវត្តន៍គំរោងការមួយចំនួន ប្រព្រឹត្តទៅមិនបានតាមកម្មវិធីដែលបានគ្រោងទុក។

ដើម្បីជំរុញល្បឿនក្នុងការស្នើសុំ និងដោះស្រាយអោយរួចពន្ធនូវការនាំចូលឧបករណ៍ សំភារៈ ក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និងជំនួយមនុស្សធម៌ រាជរដ្ឋាភិបាលបានកំណត់បែបបទ និងនីតិវិធីដូចខាងក្រោម÷

១–ស្ថាប័នអនុវត្តគំរោងចាំបាច់ត្រូវរៀបចំតារាងបញ្ជី (Master List) ឧបករណ៍ សំភារៈ នាំចូលសំរាប់ប្រើប្រាស់ក្នុងគំរោងការនីមួយៗ រួចផ្ញើជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ (កអក/គជនា) ។

២–ចំពោះសំណើនាំចូលឧបករណ៍ សំភារៈរួចពន្ធសំរាប់អនុវត្តគំរោងការ ក្នុងក្របខ័ណ្ឌជំនួយឥតសំណង (ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល) សាមីស្ថាប័នជាអ្នកអនុវត្តគំរោងការឬស្ថាប័នទទួលជំនួយ ត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសំរេចតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៣–ចំពោះសំណើនាំចូលឧបករណ៍ សំភារៈរួចពន្ធ ក្នុងក្របខ័ណ្ឌឥណទាន និងជំនួយបច្ចេកទេសផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀង (ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ...) សាមីស្ថាប័នអនុវត្តន៍គំរោងការត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេច ។

៤–ចំពោះសំណើនាំចូលឧបករណ៍ សំភារៈរួចពន្ធ ក្នុងក្របខ័ណ្ឌជំនួយមនុស្សធម៌ សាមីស្ថាប័នទទួលជំនួយនោះ ត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេច ។

៥–ឯកសារយោងសំខាន់ៗសំរាប់បំពេញបែបបទស្នើសុំមានដូចខាងក្រោម :

–កិច្ចព្រមព្រៀង ឬឯកសារដែលមានតំលៃប្រហាក់ប្រហែល

–បញ្ជីរាយនាមមុខទំនិញ Packing List

–វិក័យប័ត្រ Invoice

–អញ្ញាតប័ណ្ណ Bill of Loading

រាជរដ្ឋាភិបាលសូមស្ថាប័នទាំងអស់ យកចិត្តទុកដាក់ក្នុងការអនុវត្តន៍សារាចរនេះ អោយមានប្រសិទ្ធភាព ។

នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ | ហ៊ុន សែន

ចម្លងជូន :

–ខុទ្ទកាល័យព្រះមហាក្សត្រ

–អគ្គលេខាធិការដ្ឋានរដ្ឋសភា

–គ្រប់ក្រសួង –រដ្ឋលេខាធិការដ្ឋាន

–ខុទ្ទកាល័យសម្ដេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

–ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី២

–កាលប្បវត្តិ–ឯកសារ